**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលនៃការដោះស្រាយករណីកម្មករនិយោជិតនៃក្រុមហ៊ុន តាវាល អ៊ិនធើណេសិនណល ឯ.ក ធ្វើការប្រមូលផ្តុំតវ៉ាហូតឈានដល់ការបិទផ្លូវសាធារណៈ (ផ្លូវជាតិលេខ៣)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជន និងបងប្អូនកម្មករនិយោជិតនៃរោងចក្រ តាវាល អ៊ិនធើណេសិនណល ជ្រាបថា កាលពីព្រឹកថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៥ កម្មករនិយោជិតនៃក្រុមហ៊ុន តាវាល អ៊ិនធើណេសិនណល ឯ.ក ដែលមានអាសយដ្ឋាននៅ ផ្លូវជាតិលេខ៣ ភូមិព្រៃតាមួច និងភូមិត្រពាំងមាន ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បាននាំគ្នាផ្អាកការងារ និងប្រមូលផ្តុំធ្វើការតវ៉ា រហូតឈានដល់ការបិទផ្លូវជាតិលេខ៣ ដោយទាមទារឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួលអំឡុងពេលធ្វើកូដកម្ម និងលក្ខខណ្ឌការងារផ្សេងៗទៀតចំនួន ១៨ចំណុច។

ក្រោយពីទទួលបានព័ត៌មាននេះ ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះដល់ទីតាំងក្រុមហ៊ុនភ្លាម ដើម្បីសម្របសម្រួលនិងស្វែងរកដំណោះស្រាយ។ ជាលទ្ធផលភាគីទាំងពីរគឺតំណាងបងប្អូនកម្មករនិយោជិត ដែលបានរើសដោយបងប្អូនផ្ទាល់ និងតំណាងនិយោជកបានទទួលយកដំណោះស្រាយដោយឯកភាពសះជានឹងគ្នា រហូតដល់ទៅ ១៦ចំណុច។

ក្រសួងសូមអំពាវនាវដល់បងប្អូនកម្មករនិយោជិតទាំងអស់ ទទួលយកនូវដំណោះស្រាយដែលក្រុមហ៊ុនបានយល់ព្រម និងត្រូវសហការអនុវត្តតាម បទប្បញ្ញត្តិច្បាប់និងចៀសវាងធ្វើសកម្មភាពប៉ះពាល់ ដល់សណ្តាប់ធ្នាប់សាធារណៈ សកម្មភាពផលិតកម្មរបស់ក្រុមហ៊ុន និងផលប្រយោជន៍រួមរបស់កម្មករនិយោជិតភាគច្រើនផ្សេងទៀតដែលបាននិងកំពុងខិតខំធ្វើការនៅក្នុងរោងចក្រ។

អាស្រ័យហេតុនេះ សូមសាធារណជន និងបងប្អូនកម្មករនិយោជិត នៃក្រុមហ៊ុន តាវាល អ៊ិនធើណេសិនណល ឯ.ក ជ្រាបជាព័ត៌មាន។

ថ្ងៃសៅរ៍ ១២កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩